**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
**នាយកដ្ឋានអឺរ៉ុប**

សេចក្តីប្រកាសព័ត៌មាន

# «លទ្ធផលនៃទស្សនកិច្ចផ្លូវការរបស់ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅសាធារណរដ្ឋបារាំង»

ក្នុងឱកាសនៃដំណើរទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋបារាំងពីថ្ងៃទី១៨-១៩ ខែមករា ឆ្នាំ ២០២៤ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានមានកិច្ចសន្ទនាជាមួយ **ឯកឧត្តម អេម៉ានុយអែល ម៉ាក្រុង** ប្រធានាធិបតីនៃសាធារណរដ្ឋបារាំង នៅវិមានអេលីហ្សេ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៤។

បន្ទាប់ពី **ឯកឧត្តម អេម៉ានុយអែល ម៉ាក្រុង** បានទទួលស្វាគមន៍យ៉ាងកក់ក្តៅ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានរំលឹកពីព្រះរាជទស្សនកិច្ចផ្លូវការរបស់ **ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** នៅក្នុងខែវិច្ឆិកា ឆ្នាំ២០២៣ និងទស្សនកិច្ចការងាររបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ពេលនោះជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា កាលពីខែធ្នូ ឆ្នាំ២០២២ នៅសាធារណរដ្ឋបារាំង។ **សម្តេចធិបតី** ក៏បានសម្តែងនូវសេចក្តីសោមនស្សរីករាយ ដោយបារាំងគឺជាប្រទេសតែមួយគត់ដែលបានទទួលស្វាគមន៍ទស្សនកិច្ចរបស់ឥស្សរជនកំពូលកម្ពុជា ដល់ទៅ ៣រូប ក្នុងរយៈពេលតែ១៣ខែប៉ុណ្ណោះ។ បារាំងជាប្រទេសដំបូងគេក្នុងចំណោមបណ្តាប្រទេសអឺរ៉ុបដែល **សម្តេចធិបតី** បានអញ្ជើញបំពេញទស្សនកិច្ចផ្លូវការ ហើយ **សម្តេចធិបតី** ជាឥស្សរជនបរទេសទីមួយ ដែល **ប្រធានាធិបតី** ទទួលស្វាគមន៍នៅដើមឆ្នាំថ្មីនេះ។ ទាំងនេះគឺជាសក្ខីភាពដ៏វិសេសវិសាលចំពោះសក្តានុពលថ្មីនៅក្នុងទំនាក់ទំនងស្និទ្ធស្នាលជាប្រវត្តិសាស្ត្ររវាងកម្ពុជា និងបារាំងក្នុងរយៈពេលជាង១៨០ឆ្នាំ។

ដោយកត់សម្គាល់ឃើញនូវសន្ទុះរីកចម្រើននៅក្នុងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ថ្នាក់ដឹកនាំទាំងពីរ បានឯកភាពគ្នាលើកកម្ពស់ទំនាក់ទំនងទ្វេភាគីក្នុងគោលដៅសម្រេចបាននូវភាពជាដៃគូយុទ្ធសាស្ត្រ

ដែលជាសក្ខីភាពយ៉ាងជាក់ច្បាស់នូវភាពស៊ីជម្រៅនៃចំណងមិត្តភាពជិតស្និទ្ធ និងដ៏ល្អប្រពៃជាយូរអង្វែងរវាងប្រទេសទាំងពីរ។

ក្នុងឱកាសកិច្ចសន្ទនានេះ **សម្តេចធិបតី** បានរំលឹកស្វាគមន៍តួនាទីរបស់បារាំងក្នុងនាមជាស្ថាបនិក និងជាសហប្រធាននៃសន្និសីទទីក្រុងប៉ារីសស្តីពីកម្ពុជា ដែលបាននាំទៅសម្រេចបាននូវ **"កិច្ចព្រមព្រៀងទីក្រុងប៉ារីស"** ក្នុងឆ្នាំ១៩៩១ និងការរួមចំណែកយ៉ាងសំខាន់របស់បារាំងក្នុងការស្តារ និងអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមរបស់កម្ពុជាតាំងពីពេលនោះមក តាមរយៈទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD) ដែលបានធ្វើឱ្យកម្ពុជា ក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតទាប និងស្ថិតនៅលើមាគ៌ាឆ្ពោះទៅប្រទេសចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសចំណូលខ្ពស់នៅឆ្នាំ២០៥០។ ជាការឆ្លើយតប **ឯកឧត្តម អេម៉ានុយអែល ម៉ាក្រុង** បានបញ្ជាក់ពីការប្តេជ្ញាបន្តផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការដល់កម្ពុជា តាមរយៈទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍក្នុងទំហំទឹកប្រាក់ ២១៥លានអឺរ៉ូ ដល់វិស័យបណ្តុះបណ្តាលវិជ្ជាជីវៈ ថាមពល និងផលិតកម្មទឹកស្អាត។

**ថ្នាក់ដឹកនាំទាំងពីរ** បានលើកឡើងនូវការយកចិត្តទុកដាក់ដល់ការលើកកម្ពស់អង្គការហ្វ្រង់កូហ្វូនី ដែលកម្ពុជាជាសមាជិកស្ថាបនិកដ៏សកម្មមួយ និងរួមគ្នាជំរុញវត្តមានភាសាបារាំងនៅកម្ពុជា ដែលមានអ្នកនិយមនិយាយភាសាបារាំងច្រើនជាងគេក្នុងចំណោមបណ្តាប្រទេសនៅអាស៊ី។**ឯកឧត្តមប្រធានាធិបតី** ក៏បានបង្ហាញជំហរគាំទ្រពេញទំហឹង ចំពោះបេក្ខភាពកម្ពុជាក្នុងការធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំកំពូលហ្វ្រង់-កូហ្វូនីលើកទី២០ នៅទីក្រុងភ្នំពេញ ឆ្នាំ២០២៦ ខាងមុខ។ ជាការឆ្លើយតប **សម្តេចធិបតី** បានបញ្ជាក់ថា កម្ពុជាកំពុងត្រៀមខ្លួនរៀបចំព្រឹត្តការណ៍ដ៏សំខាន់នេះ ហើយក៏បានជូនពរបារាំងទទួលបានជោគជ័យក្នុងការធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីលើកទី១៩ និងកីឡាអូឡាំពិក និងប៉ារ៉ាឡាំពិកនៅក្នុងឆ្នាំ២០២៤ នេះ។

នៅក្នុងក្របខ័ណ្ឌនៃការជំរុញ និងលើកកម្ពស់ភាសាបារាំងដែលជាអាទិភាពសំខាន់មួយរបស់បារាំង **សម្តេចធិបតី** ក៏បានជម្រាបជូននូវគំនិតផ្តួចផ្តើមផ្ទាល់របស់ **សម្តេច** ថាភាគីបារាំងអាចពិនិត្យលទ្ធភាពបង្កើតមជ្ឈមណ្ឌលវប្បធម៌ និងភាសាប្រចាំតំបន់នៅកម្ពុជា តាមរយៈការលើកទឹកចិត្តដល់ការវិនិយោគតាមរូបមន្តភាពជាដៃគូរវាងរដ្ឋ និងឯកជន(PPP)។ ម្យ៉ាងទៀត **សម្តេចធិបតី** ក៏បានថ្លែងអំណរគុណបារាំងដែលបាន និងកំពុងជួយកម្ពុជាក្នុងការអភិរក្សបេតិកភណ្ឌ ការលើកកម្ពស់វិស័យវប្បធម៌ និងវិស័យអប់រំនៅកម្ពុជា និងសង្ឃឹមថាបារាំងនឹងបន្តជួយដល់វិស័យទាំងនេះ។ **សម្តេចធិបតី** ក៏បានស្នើភាគីបារាំងទុកលទ្ធភាពខ្លះជូនរាជរដ្ឋាភិបាលកម្ពុជា ក្នុងការកំណត់ជំនាញសិក្សារបស់និស្សិតកម្ពុជាដែលទទួលបានអាហារូបករណ៍សម្រាប់ជំនាញដែលឆ្លើយតបនឹងតម្រូវការជាអាទិភាពក្នុងការអភិវឌ្ឍប្រទេស ហើយរាជរដ្ឋាភិបាលកម្ពុជានឹងពិនិត្យលទ្ធភាពចូលរួមផ្តល់អាហារូបករណ៍ទាំងនោះផងដែរ។

ខាងផ្នែកការពារបរិស្ថាន **ឯកឧត្តមប្រធានាធិបតី** បានជម្រាបអំពីគំនិតផ្តួចផ្តើមរបស់បារាំងស្តីពីកតិកាសញ្ញាទីក្រុងប៉ារីសសម្រាប់ប្រជាជន និងភពផែនដី (Paris Pact for the People and the Planet) និងស្នើកម្ពុជាចូលរួមគាំទ្រ។ ជាការឆ្លើយតប **សម្តេចធិបតី** បានសម្តែងពីការគាំទ្ររបស់កម្ពុជាចំពោះគំនិតផ្តួចផ្តើមរបស់បារាំងនេះ និងបានជម្រាបជូន **ឯកឧត្តមប្រធានាធិបតី** អំពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការចូលរួមជាមួយអន្តរជាតិក្នុងការការពារបរិស្ថាន ព្រមទាំងជម្រាបជូនអំពីផែនការរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការកាត់បន្ថយការបំភាយកាបូន ៧០% ត្រឹមឆ្នាំ២០៣០ និងសម្រេចឱ្យបាននូវអព្យាក្រឹតកាបូនត្រឹមឆ្នាំ២០៥០។ ក្នុងគោលដៅនេះ កម្ពុជាសូមលើកទឹកចិត្តដល់ក្រុមហ៊ុនបារាំងដែលមានចំណាប់អារម្មណ៍មកវិនិយោគ នៅកម្ពុជាក្នុងវិស័យអន្តរកាលថាមពល ដែលទាំងរាជរដ្ឋាភិបាលកម្ពុជា ទាំងរដ្ឋាភិបាលបារាំងក៏ដូចជាបណ្តាប្រទេសនៅលើពិភពលោកទាំងអស់កំពុងផ្តោតការយកចិត្តទុកដាក់។

លើសពីនេះ **សម្តេចធិបតី** និង **ឯកឧត្តមប្រធានាធិបតី** ក៏បានផ្លាស់ប្តូរទស្សនៈអំពីបញ្ហាតំបន់ និងអន្តរជាតិដែលជាកង្វល់រួម ព្រមទាំងបានបញ្ជាក់សារជាថ្មីនូវការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលនៃប្រទេសទាំងពីរក្នុងការចូលរួមថែរក្សាសន្តិភាព និងសន្តិសុខសកល។

ក្នុងវិស័យសេដ្ឋកិច្ច និងពាណិជ្ជកម្ម **សម្តេចធិបតី** បានកត់សម្គាល់អំពីការកើនឡើងនូវទំហំពាណិជ្ជកម្មរវាងកម្ពុជា និងបារាំង ព្រមទាំងវត្តមានរបស់ក្រុមហ៊ុនបារាំងធំៗនៅកម្ពុជាផងដែរ រួមមានក្រុមហ៊ុនថាមពល TotalEnergies និងក្រុមហ៊ុន VINCI ជាដើមដែលកំពុងធ្វើប្រតិបត្តិការវិនិយោគនៅកម្ពុជា។

បន្ទាប់ពីបញ្ចប់កិច្ចសន្ទនាជាមួយ **ឯកឧត្តមប្រធានាធិបតី អេម៉ានុយអែល ម៉ាក្រុង** នៅថ្ងៃដដែល **សម្តេចធិបតី** ក៏បានជួបសម្តែងការគួរសមជាបន្តបន្ទាប់ជាមួយ**ឯកឧត្តម** Gérard LARCHER ប្រធានព្រឹទ្ធសភា និង**លោកជំទាវ** Yaël BRAUN-PIVET ប្រធានរដ្ឋសភានៃសាធារណរដ្ឋបារាំង ដើម្បីលើកកម្ពស់ទំនាក់ទំនងសភារវាងកម្ពុជា និងបារាំងឱ្យមានសន្ទុះថ្មី។

ក្នុងក្របខ័ណ្ឌនីតិប្បញ្ញត្តិ ភាគីកម្ពុជា និងបារាំង បានផ្តោតសំខាន់ទៅលើការបន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការឱ្យកាន់តែល្អប្រសើរ និងស៊ីជម្រៅរវាងប្រទេសទាំងពីរ ដើម្បីជាឧត្តមប្រយោជន៍ដ៏ខ្ពង់ខ្ពស់ជូនប្រទេសទាំងពីរ និងបានប្តេជ្ញាបន្តរឹតចំណងរវាងក្រុមមិត្តភាពនៃសភាទាំងពីរថ្នាក់របស់ប្រទេសទាំងពីរ។ ភាគីទាំងពីរបានបង្ហាញពីឆន្ទៈមោះមុតក្នុងការជំរុញកិច្ចការទូតសភាតាមរូបភាពនៃការផ្លាស់ប្តូរទស្សនកិច្ចរវាងថ្នាក់ដឹកនាំសភា ដើម្បីចែករំលែកបទពិសោធន៍ការងារសភា និងធ្វើកិច្ចសហប្រតិបត្តិការទ្វេភាគីទាំងក្នុងកម្រិតថ្នាក់ដឹកនាំជាន់ខ្ពស់ និងកម្រិតសមាជិកតាមតំបន់ ក៏ដូចជាកម្រិតអន្តរជាតិ។ **សម្តេចធិបតី ឯកឧត្តមប្រធានព្រឹទ្ធសភា និងលោកជំទាវប្រធានរដ្ឋសភាបារាំង** បានកត់សម្គាល់ថា

ប្រទេសទាំងពីរកម្ពុជា-បារាំងមានទស្សនវិស័យរួមគ្នាក្នុងកិច្ចសហប្រតិបត្តិការលើវិស័យនយោបាយ វប្បធម៌ សេដ្ឋកិច្ច និងអន្តរកាលថាមពល។

ក្នុងជំនួបជាមួយ **ឯកឧត្តមប្រធានព្រឹទ្ធសភាបារាំង** **ថ្នាក់ដឹកនាំទាំងពីរ**បានកត់សម្គាល់នូវភាពចាំបាច់ក្នុងការធ្វើបច្ចុប្បន្នភាពនៃអនុស្សរណៈយោគយល់គ្នារវាងស្ថាប័នព្រឹទ្ធសភានៃប្រទេសទាំងពីរ ដែលមានអាយុជាង ២៥ឆ្នាំហើយ។ **សម្តេចធិបតី** បានសូមអញ្ជើញ **ឯកឧត្តមប្រធានព្រឹទ្ធសភាបារាំង** មកបំពេញទស្សនកិច្ចនៅកម្ពុជា តាមពេលវេលាសមស្របក្នុងឆ្នាំ២០២៤នេះ ព្រមទាំងស្វាគមន៍នូវដំណើរទស្សនកិច្ចរបស់**ឯកឧត្តម** Vincent ÉBLÉ សមាជិកព្រឹទ្ធសភាបារាំង និងជាប្រធានក្រុមអន្តរសភាមិត្តភាពបារាំង-កម្ពុជា-ឡាវមកកាន់កម្ពុជាក្នុងអំឡុងខែមិនា ឆ្នាំ២០២៤ បន្ទាប់ពីការបោះឆ្នោតព្រឹទ្ធសភានីតិកាលទី៥ បានធ្វើរួចនៅខែកុម្ភៈ ឆ្នាំ២០២៤ ខាងមុខនេះ។

ក្នុងជំនួបជាមួយ **លោកជំទាវប្រធានរដ្ឋសភាបារាំង ថ្នាក់ដឹកនាំទាំងពីរ**ក៏បានពិភាក្សាផងដែរអំពីសក្តានុពល នៃតួនាទីដ៏សំខាន់របស់ប្រទេសទាំងពីរ ទាំងក្នុងក្របខ័ណ្ឌទ្វេភាគី និងពហុភាគី ក៏ដូចជាកម្រិតសកល។ ជាចុងក្រោយ **សម្តេចធិបតី** បានថ្លែងអំណរគុណចំពោះការអញ្ជើញរបស់ **លោកជំទាវប្រធានរដ្ឋសភាបារាំង** ជូនចំពោះ **សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** ប្រធានរដ្ឋសភាកម្ពុជា ដែលនឹងអញ្ជើញចូលរួមកិច្ចប្រជុំអន្តរជាតិប្រធានសភាជាស្ត្រី នៅទីក្រុងប៉ារីស ពីថ្ងៃទី៦-៧ ខែមីនា ឆ្នាំ២០២៤ ខាងមុខនេះ ដែលជាជំនួបដ៏វិសេសរវាងប្រធានសភាជាស្ត្រីក្នុងការចូលរួមចំណែកដល់ការលើកកម្ពស់សិទ្ធិស្ត្រី សមភាពយេនឌ័រ និងការពង្រឹងភាពអង់អាចរបស់ស្ត្រី។

ក្នុងក្របខ័ណ្ឌនៃដំណើរទស្សនកិច្ចផ្លូវការនេះផងដែរ **សម្តេចបធិបតី** ក៏បានជួបជាមួយ **ឯកឧត្តមហ្គាប្រីយែល អាត់តាល់** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋបារាំង នៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៤។ **សម្តេចធិបតី** បានថ្លែងអំណរគុណ និងមានក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដែល **សម្តេចធិបតី** គឺជាឥស្សរជនបរទេសទីមួយដែលត្រូវបានទទួលជួបជាមួយ **ឯកឧត្តមនាយករដ្ឋមន្ត្រី**បារាំងនៅឆ្នាំថ្មីនេះ។ ជំនួបទ្វេភាគីនេះក៏បានផ្តល់ ឱកាសជូន**ថ្នាក់ដឹកនាំទាំងពីរ**បញ្ជាក់ឡើងវិញនូវការប្តេជ្ញាចិត្តរួមគ្នា ក្នុងការលើកកម្ពស់ទំនាក់ទំនង មិត្តភាពប្រពៃណី និងស្និទ្ធស្នាលឡើងដល់កម្ពស់ថ្មីមួយ ឆ្ពោះទៅការកំណត់ផែនការសកម្មភាពដើម្បីសម្រេចនូវគោលដៅដែលបានកំណត់។

ក្នុងឱកាសស្នាក់នៅទីក្រុងប៉ារីស **សម្តេចធិបតី** បានទទួលជួប **លោកជំទាវ លួីស មូស៊ីគីវ៉ាបូ** អគ្គលេខាធិការ នៃអង្គការហ្វ្រង់កូហ្វូនី ដើម្បីពិភាក្សាអំពីបេក្ខភាពកម្ពុជាក្នុងការធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីលើកទី២០ នៅនៅទីក្រុងភ្នំពេញ ឆ្នាំ២០២៦ ផងដែរ។

ដើម្បីទាក់ទាញ និងកៀរគរការវិនិយោគបារាំងមកកម្ពុជាថែមទៀត **សម្តេចធិបតី** ក៏បានអញ្ជើញធ្វើជាអធិបតីក្នុង **វេទិកាធុរកិច្ចបារាំង-កម្ពុជា** នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៤ ដោយមានការសម្របសម្រួល

និងរៀបចំឡើងដោយសភាពាណិជ្ជកម្មកម្ពុជា និងមានការចូលរួមពីតំណាងក្រុមហ៊ុនប្រមាណ១១០ ក្នុងនោះមានក្រុមហ៊ុនចំនួន៨០ មកពីប្រទេសបារាំង និង៣០ មកពីប្រទេសកម្ពុជា។ វេទិកានេះបានបើកផ្លូវឱ្យមានការផ្លាស់ប្តូរទំនាក់ទំនង ពង្រីកឱកាស និងសិក្សាស្វែងយល់កាន់តែស៊ីជម្រៅ ក្នុងគោលបំណងបង្កើនឱកាសបន្ថែមទៀតដល់ការវិនិយោគ ព្រមទាំងលើកកម្ពស់កាលានុវត្តភាពធុរកិច្ច វិនិយោគ និងសេដ្ឋកិច្ចពាណិជ្ជកម្ម រវាងភាគីទាំងពីរ។

**សម្តេចធិបតី** ក៏បានទទួលជួបដាច់ដោយឡែកពីគ្នាជាមួយថ្នាក់ដឹកនាំក្រុមហ៊ុនបារាំងចំនួនជាង ១០ រួមមាន៖ Accor Group, TotalEnergies, VINCI Group, Alstom, EDF, Orange Group, Puy Du Fou Asia, Blue Circle, ECOLE 42, CMA CGM, PL Vista។ ក្រុមហ៊ុនទាំងនេះមានប្រតិបត្តិការលើវិស័យហេដ្ឋារចនាសម្ព័ន្ធ អាកាសចរណ៍ស៊ីវិល សណ្ឋាគារ និងបដិសណ្ឋារកិច្ច ការដឹកជញ្ជូនតាមផ្លូវដែកថាមពលកកើតឡើងវិញ បច្ចេកវិទ្យាព័ត៌មាន ឱ្យដីថល និងវិស័យផ្សេងៗទៀត។ តំណាងក្រុមហ៊ុនទាំងអស់បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងសូមកោតសរសើរដល់រាជរដ្ឋាភិបាលកម្ពុជា ដែលតែងតែបានផ្តល់បរិយាកាសអំណោយផល ការលើកទឹកចិត្ត ជាពិសេសតាមរយៈច្បាប់វិនិយោគថ្មី និងគោលនយោបាយថ្មីៗរបស់កម្ពុជា។ ក្រុមហ៊ុនក៏បានបង្ហាញពីបំណងប្រាថ្នាក្នុងការបន្តប្រតិបត្តិការ និងការធ្វើធុរកិច្ចរបស់ខ្លួន ព្រមទាំងពង្រីកគម្រោងវិនិយោគថ្មីថែមទៀតនៅកម្ពុជា។

ក្នុងស្មារតីយកចិត្តទុកដាក់ពីសុខទុក្ខ ក៏ដូចជាក្នុងគោលបំណងជម្រាបជូនពីគោលនយោបាយរាជរដ្ឋាភិបាលកម្ពុជា ដល់ប្រជាជនខ្មែរទាំងក្នុង និងក្រៅប្រទេស **សម្តេចធិបតី** ក៏បានឆ្លៀតពេលដ៏មមាញឹកនេះ ជួបសំណេះសំណាលជាមួយបងប្អូនសហគមន៍ខ្មែររស់នៅបណ្តាប្រទេសអឺរ៉ុប ដូចជាបារាំង បែលហ្ស៊ិក និងស្វីស នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៤។

ថ្ងៃសៅរ៍ ១០កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែមករា ឆ្នាំ២០២៤

